# មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាប្រារព្ធពិធីរម្លឹកខួបគម្រប់៧ឆ្នាំនៃមរណភាពបណ្ឌិត កែម ឡី




*អ្នកវិភាគការអភិវឌ្ឍសង្គម បណ្ឌិត កែម ឡី ចូលរួមវេទិកាអ្នកស្ដាប់វិទ្យុអាស៊ីសេរី កាលពីថ្ងៃទី៨ កក្កដា ២០១៦។*

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា នឹងប្រារព្ធពិធីរម្លឹកខួបគម្រប់៧ឆ្នាំនៃមរណភាពបណ្ឌិត កែម ឡី តាមរយៈសកម្មភាពផ្សេងៗគ្នាចំនួន៥ ដើម្បីបង្ហាញពីការដឹងគុណ ការនឹករលឹក និងការទាមទារយុត្តិធម៌សម្រាប់ជនរងគ្រោះ។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ហៅកាត់ថា CCHR គ្រោងនឹងរៀបចំពិធីរម្លឹកខួប៧ឆ្នាំ នៃមរណភាពលោកបណ្ឌិត កែម ឡី តាមរយៈសកម្មភាព ៥ផ្សេងៗគ្នា ដើម្បីលើកកម្ពស់ស្មារតីប្រជាពលរដ្ឋ និងយុវជនយកគំរូភាពលះបង់របស់លោកបណ្ឌិត ក្នុងការលើកកម្ពស់សេរីភាពបញ្ចេញមតិ និងលទ្ធិប្រជាធិបតេយ្យ។

សកម្មភាពដែលមជ្ឈមណ្ឌលសិទ្ធិមនុស្សគ្រោងធ្វើទាំងនោះរួមមាន ១. ការប្រកួតប្រជែងនិពន្ធ ឬតែងកំណាព្យបង្ហាញពីការនឹករឭកទៅដល់វីរភាពបណ្ឌិត កែម ឡី ចាប់ពីថ្ងៃទី១៦ មិថុនា ដល់ថ្ងៃទី១ កក្កដា។ ទី២. ការដាក់តាំងរូបបណ្ឌិតកែម ឡី នៅលើរូបភាពគម្របហ្វេសប៊ុករបស់ CCHR ពេញមួយខែកក្កដា។ ៣. ការបង្ហោះសម្រង់សម្ដីបណ្ឌិត កែម ឡី ចាប់ពីថ្ងៃទី៣ ដល់ថ្ងៃទី៩ កក្កដា នៅលើហ្វេសប៊ុកផេក CCHR។ ៤. ការរៀបចំពិធីបង្សុកូល ឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធលោកបណ្ឌិត កែម ឡី នៅថ្ងៃទី៦ ខែមិថុនា និងសកម្មភាពចុងក្រោយគេ គឺការបង្ហោះខ្សែវីដេអូខ្លី ក្រោមចំណងជើងថា ពាក្យពិត និងកម្មវិធីពិភាក្សាអំពីការនឹករឭកទៅដល់បណ្ឌិត កែម ឡី តាមវិទ្យុ។

ជុំវិញរឿងនេះ នាយកផ្នែកតស៊ូមតិនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា លោក សួន យុធ្យា ប្រាប់វិទ្យុអាស៊ីសេរី នៅថ្ងៃទី២៣ ខែមិថុនា ថា ការប្រារព្ធពិធីរំឭកខួបមរណភាពបណ្ឌិត កែម ឡី មិនត្រឹមតែមានបំណងបង្ហាញពីគំរូភាពរបស់បណ្ឌិត កែម ឡី ទៅដល់ប្រជាពលរដ្ឋ និងអ្នក

ការពារសិទ្ធិមនុស្សតែប៉ុណ្ណោះទេ ក៏ប៉ុន្តែក៏ជាយុទ្ធនាការទាមទារឱ្យរដ្ឋាភិបាល ស្វែងរកយុត្តិធម៌ជូនលោក បណ្ឌិត កែម ឡី ផងដែរ។ លោកបន្ថែមថា ការមិនផ្ដល់ភាពយុត្តិធម៌សម្រាប់គ្រួសារលោកបណ្ឌិត កែម ឡី គឺជាការបន្តអំពើនិទ្ទណ្ឌភាព ហើយក៏ជាការគំរាមកំហែងទៅដល់សកម្មជនការពារសិទ្ធិមនុស្ស និងអ្នកលើកកម្ពស់សេរីភាពបញ្ចេញមតិផងដែរ។

*«មជ្ឈមណ្ឌលសិទ្ធិមនុស្សយើងនៅតែធ្វើការដើម្បីយុត្តិធម៌បណ្ឌិត កែម ឡី គឺយើងនៅតែស្វែងរកយុត្តិធម៌ពិតប្រាកដជូនលោក និងការអំពាវនាវឱ្យអ្នកទទួលខុសត្រូវ ក្នុងការស្វែងរកយុត្តិធម៌ហ្នឹង គឺត្រូវតែស្វែងរកយុត្តិធម៌ពិតប្រាកដជូនលោកបណ្ឌិត កែម ឡី។ យើងចង់បានមូលហេតុពិតដែលលោក កែម ឡី ត្រូវបានឃាតកបាញ់សម្លាប់»*។

អ្នកស្រាវជ្រាវការអភិវឌ្ឍសង្គម និងជាអ្នកវិភាគនយោបាយដ៏មានប្រជាប្រិយភាព បណ្ឌិត កែម ឡី ត្រូវបានខ្មាន់កាំភ្លើងបាញ់សម្លាប់នៅព្រឹកថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៦ នៅឯស្តារម៉ាត (Star Mart) ក្នុងស្ថានីយលក់ប្រេងឥន្ធនៈកាល់តិច (Caltex) ក្នុងទីក្រុងភ្នំពេញ។ ការបាញ់ប្រហារនេះ កើតឡើងក្រោយពីអ្នកវិភាគរូបនេះបានផ្ដល់ការអធិប្បាយដល់បណ្ដាញព័ត៌មានអំពីការកាន់កាប់ទ្រព្យសម្បត្តិដ៏ច្រើនសន្ធឹកសន្ធាប់របស់ក្រុមគ្រួសារលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលលាតត្រដាងនៅក្នុងរបាយការណ៍អង្គការឃ្លាំមើលពិភពលោក គ្លូបល

វីតណេស (Global Witness)។ សំណុំរឿងឃាតកម្មដ៏កក្រើកនេះ តុលាការបានផ្តន្ទាទោសបុរសម្នាក់ឈ្មោះ អឿត អាង ដែលហៅខ្លួនឯងថា ជួប សម្លាប់ ឱ្យជាប់ពន្ធនាគារអស់មួយជីវិត ផ្អែកតាមចម្លើយសារភាពរបស់បុរសរូបនោះដែលថា គាត់ជាអ្នកបាញ់សម្លាប់លោក កែម ឡី ដោយសារលោក កែម ឡី មិនព្រមសងប្រាក់ជំពាក់ចំនួន ៣.០០០ដុល្លារ។ ប៉ុន្តែក្រុមគ្រួសារលោក កែម ឡី និងសូម្បីតែក្រុមគ្រួសាររបស់លោក អឿត អាង មិនជឿថា ជាការពិតនោះទេ ព្រោះលោក អឿត អាង គឺជាមនុស្សក្រីក្ររស់នៅតំបន់ដាច់ស្រយាលក្នុងខេត្តសៀមរាប មិនដែលស្គាល់គ្នា និងគ្មានលុយឯណាឱ្យលោក កែម ឡី ខ្ចីនោះទេ។ ក្រោយមានការរិះគន់ខ្លាំងៗ ពីសាធារណជន តុលាការក្រុងភ្នំពេញបានសម្រេចបំបែកសំណុំរឿងនេះជាពីរ ដើម្បីស៊ើបអង្កេតរកអ្នកពាក់ព័ន្ធផ្សេងទៀតយកមកកាត់ទោស ក៏ប៉ុន្តែតុលាការមិនបានផ្តល់ព័ត៌មានស្តីពីការវិវឌ្ឍនៃសំណុំរឿងទីពីរនេះឡើយរហូតមកដល់ពេលនេះ។

វិទ្យុអាស៊ីសេរីមិនអាចទាក់ទងប្រធានអង្គភាពនាំពាក្យរដ្ឋាភិបាល លោក ផៃ ស៊ីផាន និងអ្នកនាំពាក្យគណបក្សកាន់អំណាច លោក សុខ ឥសាន បកស្រាយជុំវិញរឿងនេះបាននៅឡើយនោះទេ នៅថ្ងៃទី២៣ ខែមិថុនា ដោយទូរស័ព្ទចូល ក៏ប៉ុន្តែមិនមានអ្នកទទួល។

ដោយឡែក ក្រុមយុវជនសកម្មនឹងការងារសង្គម ក្រុមយុវជនចលនាមាតាធម្មជាតិ និងសមាគមសម្ពន្ធនិស្សិតបញ្ញវន្តខ្មែរ ក៏គ្រោងរៀបចំពិធីរំឭកខួបនៃមរណភាពបណ្ឌិត កែម ឡី នៅថ្ងៃទី១០ ខែកក្កដា ខាងមុខនេះផងដែរ។

យុវជនចលនាមាតាធម្មជាតិ លោក ថុន រដ្ឋា លើកឡើងថា ក្រុមយុវជនចលនាមាតាធម្មជាតិ នឹងចូលរួមពិធីរំឭកខួបនៃការបាញ់សម្លាប់លោក បណ្ឌិត កែម ឡី ដើម្បីទាមទារឱ្យរដ្ឋាភិបាលផ្តល់ភាពយុត្តិធម៌ទៅដល់លោកបណ្ឌិត។ លោកបន្ថែមថា យុវជនចលនាមាតាធម្មជាតិនឹងចូលរួមការប្រារព្ធខួបមរណភាពបណ្ឌិត កែម ឡី តាមរយៈការតស៊ូមតិនៅលើបណ្តាញសង្គម និងសកម្មភាពនៅទីសាធារណៈ។

លោក ថុន រដ្ឋា៖ «*ការបាញ់សម្លាប់បណ្ឌិត កែម ឡី នេះយើងអត់ទាន់ជឿជាក់ ហើយក៏យើងអត់ទាន់ទទួលបានយុត្តិធម៌ដែលមើលឃើញថាគឺត្រូវបានផ្តល់យុត្តិធម៌មកដល់លោកបណ្ឌិត កែម ឡី ដែលជាអ្នកហ៊ាននិយាយពីការពិតនៅក្នុងសង្គម អ្នកដែលជាគំរូភាព វីរភាពសម្រាប់ពួកយើង*»។

កន្លងមក ភរិយារបស់បណ្ឌិត កែម ឡី គឺអ្នកស្រី ប៊ូ រចនា បានចោទប្រកាន់ត្រង់ៗ តាមហ្វេសប៊ុករបស់គាត់ និងចេញជាសេចក្តីថ្លែងការណ៍ថា គ្រួសាររបស់លោក ហ៊ុន សែន និងរបបលោក ហ៊ុន សែន គឺជាអ្នករៀបចំជាប្រព័ន្ធក្នុងការសម្លាប់ប្តីលោកស្រី ដូច្នេះហើយទើប

អ្នកផ្តួចផ្តើមគំនិត អ្នកផ្តល់មធ្យោបាយ និងជនដៃដល់ពិតប្រាកដ ក្នុងការសម្លាប់ប្តីរបស់លោកស្រី បន្តរស់នៅក្រៅសំណាញ់ច្បាប់៕